ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

## ក្រសួងឧស្សាហកម្ម សហការជាមួយអូស្ត្រាលី ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងវិស័យកម្មន្តសាលនៅកម្ពុជា

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា តាមរយៈកម្មវិធី CAPRED បានសហការរៀបចំសិក្ខាសាលាស្តីពី "ភាពប្រកួតប្រជែងវិស័យកម្មន្តសាល ឧស្សាហកម្មប្រតិគមន៍ និងការអភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម" ក្នុងគោលដៅលើកកម្ពស់ភាពប្រកួតប្រជែងវិស័យកម្មន្តសាលរបស់កម្ពុជា។

ឧស្សាហកម្មផ្នែកកម្មន្តសាលមានការវិវត្តរីកចម្រើនគួរឱ្យកត់សម្គាល់នៅកម្ពុជា ប៉ុន្តែវិស័យនេះត្រូវបានមើលឃើញថានៅបន្តពឹងផ្អែកខ្លាំងលើការនាំចូលវត្ថុធាតុដើម ដែលទាមទារការអភិវឌ្ឍបន្ថែម ដើម្បីបង្កើនភាពប្រកួតប្រជែងជាសាកល។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បាននិងកំពុងប្រើប្រាស់លទ្ធភាពរបស់ខ្លួន រួមនឹងជំនាញរបស់កម្មវិធី CAPRED ដើម្បីរៀបចំបង្កើតឧបករណ៍ អភិវឌ្ឍគោលនយោបាយ និងកម្មវិធីដែលមានប្រសិទ្ធភាព ចាំបាច់សម្រាប់ការធ្វើពិពិធកម្មវិស័យកម្មន្តសាល, ជំរុញខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងស្រុក, និងលើកកម្ពស់ការធ្វើសមាហរណកម្មសហគ្រាសធុនតូច និងមធ្យមទៅក្នុងខ្សែប្រវាក់តម្លៃសាកល។

ក្នុងសុន្ទរកថាបើកសិក្ខាសាលានៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានលើកឡើងថា៖ "វិស័យកម្មន្តសាលរបស់កម្ពុជាមានសក្តានុពលធំធេងសម្រាប់ការលើកកម្ពស់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារ។ សិក្ខាសាលានេះមានគោលបំណងប្រែក្លាយចំណេះដឹង និងជំនាញ ទៅជាយុទ្ធសាស្ត្រដែលអាចអនុវត្តបាន ក្នុងគោលដៅលើកកម្ពស់វិស័យកម្មន្តសាលកម្ពុជាឱ្យឈានឆ្ពោះទៅដំណាក់កាលថ្មីនៃការអភិវឌ្ឍ។"

លោក អនឌ្រីស សាប្រាក ភារធារីស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា មានប្រសាសន៍ថា៖ "ប្រទេសអូស្ត្រាលីប្តេជ្ញាចិត្តគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការធ្វើពិពិធកម្មរបស់កម្ពុជា។ តាមរយៈការពង្រឹងភាពប្រកួតប្រជែងវិស័យកម្មន្តសាល យើងកំពុងបង្កើតឱកាសសម្រាប់អាជីវកម្មក្នុងស្រុកនានាឱ្យរីកចម្រើន និងសម្រាប់វិបុលភាពរបស់ប្រជាជនកម្ពុជា។"

ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ មានបេសកកម្មជំរុញការអភិវឌ្ឍ និងឧស្សាហូបនីយកម្មនៅកម្ពុជា ស្របតាមយុទ្ធសាស្រ្តបញ្ចកោណរបស់រាជរដ្ឋាភិបាល។ ក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងវិស័យកម្មន្តសាល ក្រសួងបាននិងកំពុងជំរុញការកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មក្រុមហ៊ុនក្នុងស្រុកទៅក្នុងខ្សែច្រវាក់តម្លៃសាកល ព្រមទាំងគំនិតផ្តួចផ្តើមដូចជា ការអភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ ក្រសួងមានគោលដៅកាត់បន្ថយការពឹងផ្អែកលើការនាំចូល ជំរុញការបង្កើតការងារ និងរួមចំណែកដល់ការកសាងខឿនសេដ្ឋកិច្ច ដែលកាន់តែមានភាពធន់ និរន្តរភាព និងបរិយាបន្ន សម្រាប់កម្ពុជា។

កម្មវិធី CAPRED របស់រដ្ឋាភិបាលអូស្រ្តាលី លើកម្ពស់គំនិតផ្តួចផ្តើមទាំងនេះ ដោយផ្តល់ការគាំទ្រផ្នែកគោលនយោបាយ និងជំនួយចាំបាច់ក្នុងវិស័យសំខាន់ៗ រួមមានការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSME) ហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិ និងការលើកកម្ពស់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមជាដើម។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ MISTI៖ media@misti.gov.kh
ស្ថានទូតអូស្រ្តាលី៖ Media.Cambodia@dfat.gov.au